# សេចក្ដីប្រកាសព័ត៌មានៈ ខេមបូចាចេញផ្សាយរបាយការណ៍ដំបូងរបស់ខ្លួនអំពី “ស្ថានភាពអ្នកសារព័ត៌មានកម្ពុជាឆ្នាំ ២០២០”

*ភ្នំពេញ ថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០២១ - សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ហៅកាត់ថា ខេមបូចា) នៅថ្ងៃនេះ ចេញផ្សាយនូវរបាយការណ៍មួយដែលមានចំណងជើងថា“**ស្ថានភាពអ្នកសារព័ត៌មានកម្ពុជាឆ្នាំ២០២០**” ជាការកត់ត្រាប្រចាំឆ្នាំលើកដំបូងអំពីករណីយាយីប្រឆាំងនឹងអ្នកសារព័ត៌មាន ដែលត្រូវបានចងក្រងដោយខេមបូចាចាប់តាំងពីត្រូវបានបង្កើតឡើង។ របាយការណ៍នេះបង្ហាញពីភាពញឹកញាប់នៃការយាយីប្រឆាំងនឹងអ្នកសារព័ត៌មានដែលជារឿយៗ ត្រូវបានគេដៅដោយអយុត្តិធម៌ចំពោះការអនុវត្តសិទ្ធិស្របច្បាប់ និងសេរីភាពរបស់ពួកគេនៅក្នុងការរាយការណ៍ព័ត៌មាន។*

*ខេមបូចា បានកត់ត្រានូវការយាយីចំនួន៣៩ករណីប្រឆាំងនឹងអ្នកសារព័ត៌មានចំនួន៧២នាក់ក្នុងឆ្នាំ២០២០។ ប្រភេទនៃយាយីប្រឆាំងនឹងអ្នកសារព័ត៌មានដែលបានកើតមានឡើងច្រើនជាងគេគឺការឃុំខ្លួនក្នុងពន្ធនាគារ និងការប្រើអំពើហិង្សា។ យ៉ាងតិចណាស់មានអ្នកសារព័ត៌មានចំនួន៣១នាក់ត្រូវបានចាប់ឃុំខ្លួន (ស្មើនឹងប្រមាណ៤៣ភាគរយនៃករណីសរុប)។ អំពើហិង្សាក៏នៅតែជាហានិភ័យនៃការងាររបស់អ្នកសារព័ត៌មានផងដែរ។ អ្នកសារព័ត៌មានចំនួន២២នាក់ត្រូវបានទទួលរងការវាយដំលើរូបរាងកាយ ឬរងការគំរាមប្រើអំពើហិង្សានៅពេលកំពុងបំពេញការងារ។*

*ក្រមព្រហ្មទណ្ឌនៅតែជាឧបករណ៍ច្បាប់ដ៏មានឥទ្ធិពលមួយដែលត្រូវបានគេប្រើជាញឹកញាប់ដើម្បីបំភិតបំភ័យ និងចាប់អ្នកសារព័ត៌មានដាក់ពន្ធនាគារ។ របាយការណ៍បង្ហាញថា អ្នកសារព័ត៌មានភាគច្រើនដែលត្រូវបានចាប់ខ្លួនក្នុងឆ្នាំ ២០២០ ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ឬជំរិតទារប្រាក់តាមមាត្រា៤៩៥ និងមាត្រា ២៣២នៃក្រមព្រហ្មទណ្ឌ។ គិតត្រឹមខែធ្នូ ឆ្នាំ២០២០ យ៉ាងហោចណាស់មានអ្នកសារព័ត៌មានចំនួន១០នាក់កំពុងជាប់ពន្ធនាគារ និងស្ថិតក្រោមការឃុំខ្លួនបណ្ដោះអាសន្នដោយសាររងការចោទប្រកាន់ពីបទឧក្រិដ្ឋ*

ក្នុងនោះរួមមានលោក រស់ សុឃិត និងលោក សុខ ឧត្តម ដែលត្រូវបានផ្តន្ទាទោស និងចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍។ អ្នកសារព័ត៌មានចំនួន៨នាក់ផ្សេងទៀតកំពុងស្ថិតក្នុងការឃុំខ្លួនបណ្ដោះអាសន្នក្នុងពន្ធនាគារដោយជាប់ចោទពីបទជំរិតទារប្រាក់ ក្នុងនោះរួមមានលោក អេង ណារ៉ុង លោក ហ៊ួត ដារី លោក ឃឹម ផល្ល៊ី លោក ហេះ ហ៊ីន លោក ហាក់ សុផាន់ណា លោក អ៊ួន ប្រុស លោក ស៊ឹម សុខដា និងលោក ឈិន ប៊ុនធឿន។

ការបន្តចាប់ឃុំខ្លួន ការឃុំឃាំង និងការគំរាមកំហែងជាបន្តបន្ទាប់លើអ្នកសារព័ត៌មាន ធ្វើឱ្យខូចដល់តួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងសង្គមប្រជាធិបតេយ្យ និងធ្វើឱ្យមានការភ័យខ្លាចចំពោះអ្នកដែលចុះផ្សាយរឿងរ៉ាវ ឬករណីពាក់ព័ន្ធនឹងមន្ត្រីអ្នកមានអំណាច។

នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) លោក ណុប វី មានប្រសាសន៍ថា៖ " ការរកឃើញនេះបង្ហាញថាអ្នកសារព័ត៌មានដែលចុះផ្សាយ និងរាយការណ៍អំពីផលប្រយោជន៍របស់មន្ត្រីយោធា និងអ្នកមានអំណាចនៅតែត្រូវបានគេធ្វើទុក្ខបុកម្នេញតាមរយៈប្រព័ន្ធតុលាការដែលប្រើច្បាប់ព្រហ្មទណ្ឌជំនួសច្បាប់ស្តីពីរបបសារព័ត៌មាន ហើយត្រូវបានគេវាយដំ និងទទួលរងនូវអំពើហិង្សាជាបន្តបន្ទាប់។ យើងសូមអំពាវនាវដល់រាជរដ្ឋាភិបាល ធានានូវសុវត្ថិភាពនិងសន្តិសុខរបស់អ្នកសារព័ត៌មានទាំងអស់ដើម្បីឱ្យពួកគេអាចអនុវត្តសិទ្ធិរបស់ពួកគេក្នុងការរាយការណ៍ព័ត៌មានដោយសេរីនិងដោយគ្មានការភ័យខ្លាច "។
របាយការណ៍នេះក៏បានផ្តល់នូវអនុសាសន៍ជាច្រើនដែលផ្តោតលើសកម្មភាពជាក់លាក់សំខាន់ៗមួយចំនួនផងដែរ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
ទូរសព្ទលេខ៖ ០១២ ៥១៩ ២៦១
អ៊ីមែល៖ ed@camboja.net